**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៦៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៥១៩នាក់ នៃរោងចក្រ សហគ្រាសទាំង២៧ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង២៧ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ៣រោចខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ២៧ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 2 |
| 1 | ក្រុមហ៊ុន ជីនវីន អ៊ីនដាសស្ទ្រី ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 2 | ក្រុមហ៊ុន ស៊ី ស៊ី អេហ្វ ស៊ូមេនូហ្វេកធើរី | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 25 |
| 3 | សណ្ឋាគាររ៉ាហ្វិលរ៉ូយ៉ាល់ | ភ្នំពេញ |
| 4 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 6 | ក្រុមហ៊ុន ជីរេតព្យាណូ | សៀមរាប |
| 7 | សណ្ឋាគារ អង្គរ | សៀមរាប |
| 8 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 9 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 10 | សណ្ឋាគារ វីចេនស៊ីអង្គរ | សៀមរាប |
| 11 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |
| 12 | ក្រុមហ៊ុន ហ៊្វូដ អេន បេវើរិច សឺលូសិន | សៀមរាប |
| 13 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 14 | ក្រុមហ៊ុន ដឺ អេរៀរី | សៀមរាប |
| 15 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 16 | ភោជនីយដ្ឋានសុខៈវីវើ | សៀមរាប |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សណ្ឋាគារ | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 18 | សណ្ឋាគារ សារ៉ៃរីសត និង ស្ប៉ា | សៀមរាប |
| 19 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 20 | សណ្ឋាគារប៉ាវ៉ាឌីសអង្គរវីឡា | សៀមរាប |
| 21 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 22 | សណ្ឋាគារទ្រីឡាញ អីបេន រីហ្សត | សៀមរាប |
| 23 | ក្រុមហ៊ុន សាបារា អង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 24 | សណ្ឋាគារ សាឯមសៀមរាប | សៀមរាប |
| 25 | ក្រុមហ៊ុន ដឺ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 26 | ភោជនីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |
| 27 | សណ្ឋាគារ ឋានសួគ៌សុខា | កំពត |